ល្បែងសន្តិសុខទឹក - ប្រទេសកម្ពុជា

អ្នកលេងម្នាក់ៗអាចជាបុគ្គល ឬក្រុមតំណាងឱ្យសហគមន៍តូចមួយនៅតាមសហគមន៍នៃប្រទេសកម្ពុជា។ អ្នកលេងទាំងអស់ត្រូវតែធ្វើការសម្រេចចិត្តលើការប្រើប្រាស់ទឹក នឹងដីធ្លីដែលអាចធ្វើឱ្យមានតុល្យភាពដល់សុខុមាលភាពសហគមន៍ និងនិរន្តរភាពនៃបរិស្ថានទីជម្រាល។ ការសម្រេចចិត្តទាំងនេះអាចកំណត់ភាពធន់ជារួម ក៏ដូចជាការចំណេញនិងការខាតបង់ចំណូលសាច់ប្រាក់ (cash tokens) និងចំនួនទឹក (Water Tokens)។

ការសម្រេចចិត្តសំខាន់ៗ

សាច់ប្រាក់ (CASH TOKENS)
តំណាងលុយ

ចំនួនទឹក (WATER TOKENS)
តំណាងទឹក

កាតប្រើប្រាស់ដីធ្លី

តំណាងឱ្យការប្រើប្រាស់ដីធ្លីចំនួន៦ ដែលមានឥទ្ធិពលតែមួយគត់ទៅលើសាច់ប្រាក់ និងចំនួនទឹក

កសិកម្មពឹងផ្អែកលើទឹកភ្លៀង

កសិកម្មពឹងផ្អែកលើផលចំណេញពីប្រព័ន្ធស្រោចស្រព

កសិកម្មវៃឆ្លាតខាងអាកាសធាតុ

កសិរុក្ខកម្ម

ព្រៃការពារ

ការដាំដើមឈើដោយពឹងផ្អែកលើប្រព័ន្ធស្រោចស្រព

កាតសកម្មភាពសន្តិសុខទឹក

តំណាងឱ្យសកម្មភាពទាំង៥នៃសន្តិសុខទឹក ដែលមានឥទ្ធិពលតែមួយគត់ទៅលើសាច់ប្រាក់ ចំនួនទឹក និងកម្រិតពិន្ទុនៃភាពធន់ (សម្រាប់គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងជំងឺកើតឡើងដោយសារទឹក)

អនាម័យ

ការស្តុកទឹក


ទីតាំងប្រើប្រាស់ទឹករួមរបស់សហគមន៍


ការការពារគ្រោះទឹកជំនន់


ហេដ្ឋារចនាសម្ព័ន្ធបៃតង

គ្រាប់ឡុកឡាក់គ្រោះមហន្តរាយ

កំណត់ពីគ្រោះមហន្តរាយណាមួយ (គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ឬជំងឺកើតដោយសារទឹក) ដែលប៉ះពាល់ដល់អ្នកលេង។

- ជំងឺកើតដោយសារទឹក
- គ្រោះរាំងស្ងួត
- គ្រោះទឹកជំនន់

កាតសហគមន៍

តំណាងឱ្យបរិស្ថាន នយោបាយ សង្គម ឬព្រឹត្តិការណ៍ដទៃទៀត ដែលជះឥទ្ធិពលតែមួយគត់ទៅលើសាច់ប្រាក់ និងចំនួនទឹក។

កាតទីជម្រាល

តំណាងឱ្យបរិស្ថាន នយោបាយ សង្គម ឬព្រឹត្តិការណ៍ដទៃទៀត ដែលជះឥទ្ធិពលជាវិជ្ជមាន ឬអវិជ្ជមានទៅលើសាច់ប្រាក់ និងចំនួនទឹក ដែលផ្លាស់ប្តូរទៅវិញទៅមករវាងអ្នកលេង។

កាតអាងទន្លេ

តំណាងឱ្យទីតាំងខ្សែទឹកខាងក្រោម ឬខ្សែទឹកខាងលើរបស់អ្នកលេងម្នាក់ៗ។

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

ការណែនាំអំពីរបៀបលេងល្បែង

1. **កាតអាងទន្លេ:** អ្នកលេងជ្រើសរើសកាតអាងទន្លេមួយ ដើម្បីកំណត់ថាតើអ្នកណាជា "ខ្សែទឹកខាងលើ" ឬ "ខ្សែទឹកខាងក្រោម" ដែលនៅថេរក្នុងការប្រកួត។
2. **ការចែកសាច់ប្រាក់ជាលើកដំបូង:** នៅជុំទី១ អ្នកសម្របសម្រួលចែកសាច់ប្រាក់ចំនួន១០ដល់អ្នកលេងម្នាក់ៗ។ បន្ទាប់ពីជុំទី១ អ្នកលេងម្នាក់ៗចាប់ផ្តើមជាមួយសាច់ប្រាក់ដែលធ្វើឡើងនៅចុងបញ្ចប់នៃជុំទីមួយ។
3. **ថវិកាទឹក:** អ្នកសម្របសម្រួលចែកចំនួនទឹកដល់អ្នកលេងម្នាក់ៗដែលតំណាងទឹកពីទន្លេ(ស្ទឹងបឹងបួ) ទឹកភ្លៀង ទឹកក្រោមដី ឬប្រភពផ្សេងៗទៀត។ ចំនួនដែលបានចែកក្នុងជុំនីមួយៗមានការថយចុះជាបន្តបន្ទាប់ ដែលតំណាងឱ្យផលប៉ះពាល់សក្តានុពលនៃការប្រែប្រួលអាកាសធាតុ និងការថយចុះនៃការទទួលបានទឹក៖

ជុំទី១	ជុំទី២	ជុំទី៣	ជុំទី៤
20	18	16	14

4. **ការប្រើប្រាស់ដី:** នៅក្នុងជុំទី១ អ្នកលេងទាំងអស់ចាប់ផ្តើមជាមួយនឹងសំណុំនៃកាតប្រើប្រាស់ដីធ្លីចំនួន៤ ដែលអ្នកសម្របសម្រួលបានចែកឱ្យ។ បន្ទាប់ពីជុំទី១ អ្នកលេងម្នាក់ៗអាចទិញកាតប្រើប្រាស់ដីធ្លី ដោយប្រើសាច់ប្រាក់ដើម្បីជំនួសសាច់ប្រាក់ដែលមានជាក់ស្តែង។
5. **ការទទួលបានចំណូល និងការកាត់ចំណាយលើការប្រើប្រាស់ដីធ្លី:** ផ្អែកលើការប្រើប្រាស់ដីធ្លីដែលបានជ្រើសរើសដោយអ្នកលេងម្នាក់ៗ អ្នកសម្របសម្រួលប្រគល់សាច់ប្រាក់ដែលរកបាន និងចំនួនទឹកដែលរកបាន ឬត្រូវការសម្រាប់ការប្រើប្រាស់ដីធ្លី។
6. **ការចំណាយលើជីវភាពសហគមន៍:** អ្នកលេងត្រូវតែបង់ថ្លៃជីវភាពក្នុងសហគមន៍ជាសាច់ប្រាក់ដល់អ្នកសម្របសម្រួល ដើម្បីរ៉ាប់រងលើចំណាយជាមូលដ្ឋាន (ការអប់រំ ម្ហូបអាហារ សុខភាព។ ល។) ក្នុងជុំនីមួយៗ។ ការចំណាយទាំងនេះ កើនឡើងរាល់ជុំដើម្បីតំណាងឱ្យតម្រូវការកើនឡើង និងកំណើនប្រជាជន៖

ជុំទី១	ជុំទី២	ជុំទី៣	ជុំទី៤
6	8	10	12

7. **តម្រូវការទឹករបស់សហគមន៍:** អ្នកសម្របសម្រួល ប្រមូលចំនួនទឹកសម្រាប់តម្រូវការទឹករបស់សហគមន៍ ដើម្បីរ៉ាប់រងលើតម្រូវការទឹកជាមូលដ្ឋាន (ទឹកបរិភោគ អនាម័យ ចម្អិនអាហារជាដើម)។ តម្រូវការទាំងនេះ កើនឡើងរាល់ជុំដើម្បីតំណាងឱ្យតម្រូវការកើនឡើង និងកំណើនប្រជាជន៖

ជុំទី១	ជុំទី២	ជុំទី៣	ជុំទី៤
0	1	2	3

8. **សកម្មភាពសន្តិសុខទឹក:** អ្នកលេងត្រូវជ្រើសរើសថាតើត្រូវវិនិយោគលើសកម្មភាពសន្តិសុខទឹក ដើម្បីចៀសវាងផលប៉ះពាល់គ្រោះមហន្តរាយដែលអាចកើតមាន (សូមមើលខាងក្រោម)។ អ្នកសម្របសម្រួលត្រូវប្រមូលសាច់ប្រាក់សម្រាប់ចំណាយលើសកម្មភាពសន្តិសុខទឹកដែលបានទិញ និងចែកចំនួនទឹកដែលទទួលបានពីសកម្មភាពសន្តិសុខទឹកដែលមានស្រាប់។
9. **គ្រោះមហន្តរាយ:** ក្នុងជុំនីមួយៗ អ្នកសម្របសម្រួលត្រូវរមៀលគ្រាប់ឡុកឡាក់គ្រោះមហន្តរាយ ដើម្បីកំណត់ថាតើគ្រោះមហន្តរាយមួយណាដែលនឹងជះឥទ្ធិពលដល់អ្នកលេង។ អ្នកលេងអាចចៀសវាងផលប៉ះពាល់នៃគ្រោះមហន្តរាយជាមួយនឹងកម្រិតពិន្ទុនៃភាពធន់ដែលបានកើនឡើងពីកាតសកម្មភាពសុវត្ថិភាពទឹករបស់ពួកគេ។ កម្រិតពិន្ទុនៃភាពធន់ត្រូវការជាចាំបាច់ដើម្បីចៀសវាងគ្រោះមហន្តរាយកើនឡើងក្នុងជុំនីមួយៗ ដើម្បីតំណាងឱ្យផលប៉ះពាល់ដែលកំពុងកើនឡើងដោយសារការប្រែប្រួលអាកាសធាតុ ក៏ដូចជាផលប៉ះពាល់អវិជ្ជមានដល់ចំនួនទឹក និងសាច់ប្រាក់ផងដែរ។

	ជុំទី១	ជុំទី២	ជុំទី៣	ជុំទី៤
កម្រិតពិន្ទុនៃភាពធន់ដើម្បីចៀសវាងគ្រោះមហន្តរាយនីមួយៗ (ជំងឺកើតដោយសារទឹក, គ្រោះរាំងស្ងួត ឬទឹកជំនន់)	+3	+4	+5	+6
ផលប៉ះពាល់អវិជ្ជមានទាំងចំនួនទឹក និងសាច់ប្រាក់ ប្រសិនបើកម្រិតពិន្ទុនៃភាពធន់មិនបានឆ្លើយតបគ្រប់គ្រាន់	-3	-4	-5	-6

10. **កាតសហគមន៍:** អ្នកលេងម្នាក់ៗគូរកាតឱកាសសហគមន៍មួយ។ អ្នកសម្របសម្រួល ត្រូវប្រមូលឬចែកសាច់ប្រាក់និងចំនួនទឹកទៅតាមជាក់ស្តែង។
11. **កាតទីជម្រាល:** អ្នកសម្របសម្រួល គូរកាតឱកាសទីជម្រាលមួយដែលត្រូវអនុវត្តចំពោះអ្នកលេងទាំងអស់។ អ្នកលេង ត្រូវផ្លាស់ប្តូរគ្នារវាងសាច់ប្រាក់ និងចំនួនទឹកទៅវិញទៅមក អាស្រ័យលើទីតាំងខ្សែទឹកខាងលើ ឬខ្សែទឹកខាងក្រោម។
12. **តុល្យភាពចំនួនទឹក និងសាច់ប្រាក់:** ចំនួនទឹក និងសាច់ប្រាក់មានតុល្យភាពនៅចុងបញ្ចប់នៃជុំនីមួយៗ។ សម្រាប់រាល់ចំនួនទឹក ឬសាច់ប្រាក់ "អវិជ្ជមាន" (ឧទាហរណ៍ នៅពេលអ្នកលេងមិនអាចទូទាត់ថ្លៃតម្រូវការទឹក ថ្លៃចំណាយក្នុងជីវភាព ឬកាតនានាដែលអាចមាន) សាច់ប្រាក់ ឬចំនួនទឹក ចំនួនពីរត្រូវតែទូទាត់សងរៀងៗខ្លួន។ អ្នកសម្របសម្រួល ត្រូវប្រមូលសាច់ប្រាក់ និងចំនួនទឹកទាំងអស់ទៅតាមជាក់ស្តែង។ ប្រសិនបើអ្នកលេងណាមិនមានសាច់ប្រាក់ និងចំនួនទឹកគ្រប់គ្រាន់ក្នុងការទូទាត់សងដើម្បីទទួលបានបរិមាណទឹកអប្បបរមាដែលអាចអនុញ្ញាតបានចំនួនទឹក 0 និងសាច់ប្រាក់ 0 ទេនោះ ពួកគេនឹងមិនអាចបន្តទៅវគ្គបន្ទាប់បានឡើយ។
13. **សង្ខេបជុំ:** អ្នកសម្របសម្រួលត្រូវកត់ចំណាំលើចំនួនទឹក និងសាច់ប្រាក់សរុប។ អ្នកលេងត្រូវអនុវត្តសកម្មភាពការប្រើប្រាស់ដីធ្លី សន្តិសុខទឹក និងប្រាក់ចំណូលលើសពីជុំបន្តបន្ទាប់ ប៉ុន្តែត្រូវដាក់ចំនួនទឹកដាច់ដោយឡែក។
14. **ចំនួនជុំ:** ត្រូវលេងចំនួន៤ជុំ។ អនុវត្តជំហានទី២ដល់១២ ម្តងទៀត។
15. **ចុងបញ្ចប់ល្បែង:** អ្នកសម្របសម្រួល ត្រូវចោទជាសំនួរទៅកាន់អ្នកលេងអំពីលទ្ធផលជុំ និងពិភាក្សាអំពីផលប៉ះពាល់លើជម្រើសនៃការប្រើប្រាស់ដីធ្លី កាតឱកាស និងគ្រោះមហន្តរាយនានា។ អ្នកសម្របសម្រួល ត្រូវសម្រួលការពិភាក្សាអំពីរបៀបដែលល្បែងនេះត្រូវឈ្នះ និងចាញ់ និងរបៀបដែលល្បែងនេះត្រូវអនុវត្តចំពោះសហគមន៍។

ការប្រើប្រាស់ដីធ្លី ១

ការប្រើប្រាស់ដីធ្លី ២

ការប្រើប្រាស់ដីធ្លី ៣

ការប្រើប្រាស់ដីធ្លី ៤

ទន្លេ ស្ទឹង បឹងបួ ឬប្រភពទឹកនានា

កាតអាងទន្លេ
ខ្សែទឹកខាងលើ

កាតអាងទន្លេ
ខ្សែទឹកខាងក្រោម

កាតអាងទន្លេ
ខ្សែទឹកខាងក្រោម

កសិកម្មពឹងផ្អែកលើទឹកភ្លៀង

សាច់ប្រាក់

ចំណាយម្តង

-2

ដើម្បីប្តូរទៅការប្រើប្រាស់ដីនេះ

សាច់ប្រាក់ទទួលបានប្រចាំឆ្នាំ

+3

ដែលរកបានដោយការប្រើប្រាស់ដីនេះ

ចំនួនទឹក

ផលប៉ះពាល់កម្រិតឆ្ងាយពីប្រភពទឹក

-4

ផលប៉ះពាល់កម្រិតជិតប្រភពទឹក

-7

USAID FROM THE AMERICAN PEOPLE

SWP SUSTAINABLE WATER PARTNERSHIP

WINROCK INTERNATIONAL

កសិកម្មពឹងផ្អែកលើផលចំណេញ ពីប្រព័ន្ធស្រោចស្រព



សាច់ប្រាក់

ចំណាយម្តង	សាច់ប្រាក់ទទួលបានប្រចាំឆ្នាំ
-7	+10
ដើម្បីប្តូរទៅការប្រើប្រាស់ដីនេះ	*ដែលរកបានដោយការប្រើប្រាស់ដីនេះ*

ចំនួនទឹក

ផលប៉ះពាល់កម្រិតឆ្ងាយពីប្រភពទឹក	ផលប៉ះពាល់កម្រិតជិតប្រភពទឹក
-8	-10

កសិកម្មឆ្លាតវៃ ខាងអាកាសធាតុ

សាច់ប្រាក់

ចំណាយម្តង	សាច់ប្រាក់ទទួលបានប្រចាំឆ្នាំ
-2	+5
ដើម្បីប្តូរទៅការប្រើប្រាស់ដីនេះ	*ដែលរកបានដោយការប្រើប្រាស់ដីនេះ*

ចំនួនទឹក

ផលប៉ះពាល់កម្រិតឆ្ងាយពីប្រភពទឹក	ផលប៉ះពាល់កម្រិតជិតប្រភពទឹក
-2	-4

USAID
FROM THE AMERICAN PEOPLE

SWP
SUSTAINABLE WATER PARTNERSHIP

WINROCK
INTERNATIONAL

កសិរុក្ខកម្ម

សាច់ប្រាក់

ចំណាយម្តង

-3

ដើម្បីប្តូរទៅការប្រើប្រាស់ដីនេះ

សាច់ប្រាក់ទទួលបានប្រចាំឆ្នាំ

+4

ដែលរកបានដោយការប្រើប្រាស់ដីនេះ

ចំនួនទឹក

ផលប៉ះពាល់កម្រិតឆ្ងាយពីប្រភពទឹក

0

ផលប៉ះពាល់កម្រិតជិតប្រភពទឹក

-1

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

ព្រៃការពារ



សាច់ប្រាក់

ចំណាយម្តង	សាច់ប្រាក់ទទួលបាន ប្រចាំឆ្នាំ	
0	+1	+2
ដើម្បីប្តូរទៅ ការប្រើប្រាស់ដីនេះ	*ជុំនៃការទិញ*	*ជុំបន្ទាប់*

ចំនួនទឹក

ផលប៉ះពាល់ កម្រិតឆ្ងាយពីប្រភពទឹក		ផលប៉ះពាល់ កម្រិតជិតប្រភពទឹក	
+2	+3	+3	+4
ជុំនៃការទិញ	*ជុំបន្ទាប់*	*ជុំនៃការទិញ*	*ជុំបន្ទាប់*

ការដាំដើមឈើដោយផ្អែកលើប្រព័ន្ធស្រោចស្រព



សាច់ប្រាក់

ចំណាយម្តង

-3

ដើម្បីប្តូរទៅការប្រើប្រាស់ដីនេះ

សាច់ប្រាក់ទទួលបានប្រចាំឆ្នាំ

ជុំនៃការទិញ	ជុំបន្ទាប់
+5	+6

ចំនួនទឹក

ផលប៉ះពាល់ កម្រិតឆ្ងាយពីប្រភពទឹក

ជុំនៃការទិញ	ជុំបន្ទាប់
-2	-3

ផលប៉ះពាល់ កម្រិតជិតប្រភពទឹក

ជុំនៃការទិញ	ជុំបន្ទាប់
-3	-4

USAID FROM THE AMERICAN PEOPLE

SWP SUSTAINABLE WATER PARTNERSHIP

WINROCK INTERNATIONAL

អនាម័យ

[ឧ. បង្គន់, ការរក្សាអនាម័យល្អប្រសើរ]



សាច់ប្រាក់

-7

ការចំណាយទុន

ចំនួនទឹក

+4

អត្ថប្រយោជន៍

កម្រិតពិន្ទុនៃភាពធន់

- ជំងឺ: ៣
- គ្រោះរាំងស្ងួត: ១
- គ្រោះទឹកជំនន់: ២

ចំនួនប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់សម្រាប់ទិញ: **គ្មានដែនកំណត់**

ការស្តុកទឹក

[ឧ. ស្នុកទឹក, ធុងត្រងទឹកភ្លៀង, ស្រះ, អាងស្តុក]

សាច់ប្រាក់

-4

ការចំណាយទុន

ចំនួនទឹក

+3

អត្ថប្រយោជន៍

កម្រិតពិន្ទុនៃភាពធន់

ជំងឺ: ២

គ្រោះរាំងស្ងួត: ៣

គ្រោះទឹកជំនន់: ១

ចំនួនប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់សម្រាប់ទិញ: **គ្មានដែនកំណត់**

ទីតាំងប្រើប្រាស់ទឹករួម របស់សហគមន៍

[ការបរិភោគទឹកលើដី, ទឹកក្រោមដី]



សាច់ប្រាក់

-5

ការចំណាយទុន

ចំនួនទឹក

+4

អត្ថប្រយោជន៍

កម្រិតពិន្ទុនៃភាពធន់

- ជំងឺ: ២
- គ្រោះរាំងស្ងួត: ៣
- គ្រោះទឹកជំនន់: ១

ចំនួនប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់សម្រាប់ទិញ: **ចំនួន១ ក្នុងមួយជុំ ច្រើនបំផុត ៣**

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

ការការពារគ្រោះទឹកជំនន់

[លូបង្ហូរ, ទំនប់ស្រែ ជញ្ជាំងការពារទឹកជំនន់]



សាច់ប្រាក់

-6

ការចំណាយទុន

ចំនួនទឹក

+3

អត្ថប្រយោជន៍

កម្រិតពិន្ទុនៃភាពធន់

- ជំងឺ: ២
- គ្រោះរាំងស្ងួត: ១
- គ្រោះទឹកជំនន់: ៣

ចំនួនប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់សម្រាប់ទិញ: **ចំនួន១ ក្នុងមួយជុំ**

ហេដ្ឋារចនាសម្ព័ន្ធបៃតង

[គម្របរុក្ខជាតិបៃតងសម្រាប់ការពារប្រភពទឹក, ទ្រនាប់ការពារធម្មជាតិ, ផ្លូវទឹកហូរតាមស្មៅ, ខ្សែទឹក, និងទ្រនាប់ការពារឆ្នេរ]



សាច់ប្រាក់

-3

ការចំណាយទុន

ចំនួនទឹក

+2

អត្ថប្រយោជន៍

កម្រិតពិន្ទុនៃភាពធន់

- ជំងឺ: ១
- គ្រោះរាំងស្ងួត: ២
- គ្រោះទឹកជំនន់: ៣

ចំនួនប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់សម្រាប់ទិញ: **គ្មានដែនកំណត់**

USAID FROM THE AMERICAN PEOPLE

SWP SUSTAINABLE WATER PARTNERSHIP

WINROCK INTERNATIONAL

កាតសហគមន៍

លោកនាយករដ្ឋមន្ត្រីបានចេញបទបញ្ជាថា វដ្តស្រូវមានតែមួយដងប៉ុណ្ណោះដែលអាចដាំបានក្នុងមួយឆ្នាំ ដោយសារតែគ្រោះរាំងស្ងួត ប៉ុន្តែអ្នកជិតខាងមិនស្តាប់តាមការណែនាំ ហើយបន្តដាំដុះចំនួនពីរវដ្តស្រូវដែលជាហេតុនាំឱ្យបរិមាណទឹកត្រូវថយចុះ។ - ៣ ទឹក: ប្រសិនបើអ្នកជិតខាងនៅខាងស្តាំអ្នក មានការប្រើប្រាស់ដីស្រោចស្រព។

-3

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតសហគមន៍

សហគមន៍របស់អ្នកបានទទួលប្រាក់កម្ចីដើម្បីសាងសង់អាងស្តុកទឹកដែលអាចកាត់បន្ថយភាពតានតឹង ដោយសារកង្វះខាតទឹកនៅក្នុងរដូវប្រាំង ធ្វើឱ្យប្រសើរឡើងនូវសុខភាព និងមានទឹកប្រើប្រាស់កាន់តែច្រើនឡើង ទទួលបានហេដ្ឋារចនាសម្ព័ន្ធអាងស្តុកទឹកចំនួន ១ ជាមួយនឹងអត្ថប្រយោជន៍នៅជុំបន្ទាប់។

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតសហគមន៍

ការប្រើប្រាស់ជីច្រើនលើសលុប ជាហេតុនាំឱ្យមានលំហូរទឹកកាន់តែខ្លាំងចូលក្នុងទន្លេ ស្ទឹង បឹងបួ និងបង្កើតការចម្លងរោគក្នុងទឹកទន្លេរបស់អ្នក -៣ ទឹក លុះត្រាតែអ្នកមានហេដ្ឋារចនាសម្ព័ន្ធបៃតង ដែលផ្តល់ការការពារប្រភពទឹក និងកំណត់កម្រិតនៃការខូចខាត -1 ទឹក។

-3

-1

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតសហគមន៍

ថ្លៃចំណាយលើជីបានកើនឡើង៖
-1 សាច់ប្រាក់ សម្រាប់ការប្រើប្រាស់ដីនីមួយៗ លើកលែងតែកសិកម្មឆ្លាតវៃខាងអាកាសធាតុ និងព្រៃឈើ។

-1

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតសហគមន៍

ហ្វូងមមាចត្នោតកើតមានពាសពេញ
ហើយមនុស្សគ្រប់គ្នានៅក្នុងសហគមន៍
របស់អ្នកខូចខាតដំណាំរបស់ពួកគេ
-៣ សាច់ប្រាក់ -២ ទឹក។

-3

-2

កាតសហគមន៍

ប្រតិបត្តិករអេកូទេសចរណ៍ចូលមកក្នុង
សហគមន៍របស់អ្នកដោយសារមាន
ព្រៃការពារ។ +៣ សាច់ប្រាក់ ប្រសិនបើ
អ្នកមានកាតប្រើប្រាស់ដីព្រៃណាមួយ។

+3

កាតសហគមន៍

សហគមន៍របស់អ្នកបានវិនិយោគលើទ្រនាប់
ការពារខ្សែទឹក ដើម្បីបង្ការការប្រើប្រាស់ថ្នាំពុល
និងជីកសិកម្ម ហូរចូលទៅក្នុងប្រឡាយ និង
ខ្សែទឹក។ ជាលទ្ធផល តាមបណ្តាញផ្លូវទឹក
មានត្រីកាន់តែច្រើនឡើង ច្រាំងទន្លេកាន់តែរឹងមាំ
ហើយរិតតែមានសុវត្ថិភាពក្នុងការនេសាទ។
ប្រការនេះជួយបង្កើនជីវភាព និងបង្អាក់សត្វ
ពាហនៈមិនឱ្យចូលទៅលុកលុយជិតទន្លេបាន
+ ៣ សាច់ប្រាក់ និង +២ ទឹក។

+3

+2

កាតសហគមន៍

នៅក្នុងឆ្នាំណាដែលគ្រាប់ស្វាយចន្ទី
ត្រូវប៉ាន់ តម្លៃវាមានការកើនឡើង។
ប្រសិនបើអ្នកមានចម្ការដើមឈើ
+4 សាច់ប្រាក់។

+4

កាតសហគមន៍

នៅឆ្នាំនេះមានការកើនឡើងនូវការប្រកួតប្រជែងលើបញ្ហាទឹករវាងសហគមន៍ក្នុងតំបន់ ដែលជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយលទ្ធភាពទទួលបានទឹក លើកលែងតែអ្នកមានទីតាំងប្រើប្រាស់ទឹករួមរបស់សហគមន៍ ឬអាងស្តុកទឹក -៣ សាច់ប្រាក់ -២ ទឹក។

-3

-2

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតសហគមន៍

មានយុទ្ធនាការមួយស្តីពីការផ្លាស់ប្តូរឥរិយាបថតាមរយៈការប្រាស្រ័យទាក់ទងនៅតំបន់ទីជម្រាល ដើម្បីលើកកម្ពស់អនាម័យស្អាត និងការអនុវត្តការគ្រប់គ្រងទឹកឱ្យបានល្អប្រសើរ។ ជាលទ្ធផល មនុស្សកាន់តែច្រើនចាប់ផ្តើមទទួលយកការអនុវត្តទឹកស្អាត និងអនាម័យបានល្អប្រសើរជាងមុន +២ ទឹក។

+2

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតសហគមន៍

ជំងឺរាតត្បាតទូទាំងពិភពលោក កាត់បន្ថយតម្រូវការនាំចេញ កាត់បន្ថយការធ្វើចំណាកស្រុករបស់កម្មករវិស័យកសិកម្ម ដែលអាចជួយជំរុញក្នុងការដាំដុះ និងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចក្នុងស្រុក -៤ សាច់ប្រាក់ សម្រាប់ផលប៉ះពាល់លើជីវភាព។

-4

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតសហគមន៍

អ្នកបានវិនិយោគលើឧបករណ៍កសិកម្មទំនើបជាងមុន ដូចជាការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធធារាសាស្ត្រ ការដាំដុះ និងឧបករណ៍ស្តុក ដើម្បីបង្កើនទិន្នផល និងកាត់បន្ថយការខាតបង់ស្រូវអង្ករ + ៣ សាច់ប្រាក់ + ២ ទឹក ប្រសិនបើអ្នកមានដីកសិកម្ម។

+3

+2

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតសហគមន៍

កសិដ្ឋានចិញ្ចឹមត្រីត្រូវបានបង្កើតឡើងនៅលើដីរបស់អ្នក ដើម្បីជាការបង្កើនប្រាក់ចំណូល ប៉ុន្តែវាបង្កផលប៉ះពាល់ដល់គុណភាពទឹកនៅក្បែរនោះ +៣ សាច់ប្រាក់ និង -1 ទឹក។

+3 -1

កាតសហគមន៍

អណ្តូងមួយក្នុងមូលដ្ឋាន ត្រូវបានធ្វើតេស្តឃើញវិជ្ជមានកម្រិតជាតិអាសេនិចដែលមិនមានសុវត្ថិភាពសម្រាប់ប្រើប្រាស់ បង្កការគម្រាមកំហែងដល់សុខភាពមនុស្ស ហើយជាហេតុធ្វើឱ្យទឹកនោះគ្មានសុវត្ថិភាពសម្រាប់បរិភោគ។ លទ្ធភាពទទួលបានទឹកដែលមានសុវត្ថិភាពក្នុងតំបន់ត្រូវថយចុះ -៣ ទឹក។

-3

USAID FROM THE AMERICAN PEOPLE SWP SUSTAINABLE WATER PARTNERSHIP WINROCK INTERNATIONAL

កាតសហគមន៍

ដោយសារតែការគម្រាមកំហែងដែលនឹងកើតពីការផ្លាស់ប្តូរលំនាំអាកាសធាតុ ប្រសិនបើអ្នកធ្វើកសិកម្មដែលពឹងផ្អែកលើទឹកភ្លៀង នោះអ្នកនឹងប្រឈមចំពោះហានិភ័យខ្ពស់ ជាពិសេសទាំងគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ ព្រមទាំងអាចបាត់បង់ផលដំណាំរបស់អ្នកផងដែរ -២ ទឹក, -២ សាច់ប្រាក់។

-2 -2

USAID FROM THE AMERICAN PEOPLE SWP SUSTAINABLE WATER PARTNERSHIP WINROCK INTERNATIONAL

កាតសហគមន៍

យុទ្ធសាស្ត្ររេដបូកក្នុងប្រទេសត្រូវបានអនុវត្ត តាមរយៈការផ្តល់រង្វាន់លើកទឹកចិត្តដល់ការចៀសវាងការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលនៅក្នុងសហគមន៍មូលដ្ឋាន ដោយទទួលបានប្រភពមូលនិធិពីសហគមន៍អន្តរជាតិ។ ប្រសិនបើអ្នកមានការប្រើប្រាស់ដីព្រៃការពារ +៣ សាច់ប្រាក់ ឬក៏គ្មានព្រៃការពារ ប៉ុន្តែមានការប្រើប្រាស់ដីដាំដុះ +២ សាច់ប្រាក់។

+3 +2

USAID FROM THE AMERICAN PEOPLE SWP SUSTAINABLE WATER PARTNERSHIP WINROCK INTERNATIONAL

កាតឱកាសទីជម្រាល

ការទូទាត់ថ្លៃសេវាកម្មបរិស្ថានត្រូវបានណែនាំសម្រាប់តំបន់ទីជម្រាលដែលធ្វើឡើងដោយក្រសួងបរិស្ថាន តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលរវាងសហគមន៍ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម ។ ប្រសិនបើអ្នកលេងនៅខ្សែទឹកខាងលើមានព្រៃណាមួយ អ្នកលេងម្នាក់ៗនៃខ្សែទឹកខាងក្រោម ត្រូវទូទាត់ឱ្យអ្នកលេងនៃខ្សែទឹកខាងលើ ចំនួនសាច់ប្រាក់១ ហើយអ្នកលេងខ្សែទឹកខាងលើត្រូវផ្តល់ចំនួនទឹក១ ដល់អ្នកលេងម្នាក់ៗនៃខ្សែទឹកខាងក្រោមវិញ។

+1 +1

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតឱកាសទីជម្រាល

គម្រោងប្រព័ន្ធធារាសាស្ត្រដ៏សំខាន់មួយត្រូវបានអនុវត្តនៅក្នុងសហគមន៍ខ្សែទឹកខាងលើ ដែលនាំឱ្យមានការទាញយកទឹកមកប្រើប្រាស់ និងលំហូរទឹកទន្លេកាន់តែតិចតួចទៅៗនៅខ្សែទឹកខាងក្រោម។ ប្រសិនបើអ្នកលេងនៃខ្សែទឹកខាងលើ មានកាតប្រើប្រាស់ដីកសិកម្មដោយពឹងផ្អែកលើប្រព័ន្ធស្រោចស្រព ឬដីដាំដើមឈើ នោះអ្នកលេងនៃខ្សែទឹកខាងក្រោមត្រូវផ្តល់ចំនួនទឹក២ ដល់អ្នកលេងនៃខ្សែទឹកខាងលើ។

+2

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតឱកាសទីជម្រាល

ការពិភាក្សារវាងសហគមន៍ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម អាចជួយកាត់បន្ថយទំនាស់សិទ្ធិនៃការប្រើប្រាស់ទឹក ហើយនាំឱ្យមានការចែកចាយទឹកកាន់តែមានសមធម៌។ អ្នកលេងនៃខ្សែទឹកខាងលើត្រូវផ្តល់ឱ្យអ្នកលេងនៃខ្សែទឹកខាងក្រោមម្នាក់ៗ ចំនួនទឹក១។

+1

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតឱកាសទីជម្រាល

ដីសម្បទានសេដ្ឋកិច្ច ត្រូវបានផ្តល់ដល់សហគមន៍នៅខ្សែទឹកខាងលើ ដើម្បីអភិវឌ្ឍវិស័យកសិឧស្សាហកម្មនៅលើដីព្រៃពីមុន ដែលបង្កើនដល់ការបំពុលទឹក និងការទាញយកទឹកមកប្រើប្រាស់។ ប្រសិនបើអ្នកលេងនៃខ្សែទឹកខាងក្រោមមានហេដ្ឋារចនាសម្ព័ន្ធបៃតង នោះពួកគេម្នាក់ៗត្រូវផ្តល់ឱ្យអ្នកលេងនៃខ្សែទឹកខាងលើម្នាក់ៗចំនួនទឹក២។

+2

USAID FROM THE AMERICAN PEOPLE
SWP SUSTAINABLE WATER PARTNERSHIP
WINROCK INTERNATIONAL

កាតឱកាសទីជម្រាល

សណ្ឋាគារដ៏ធំមួយត្រូវបានសាងសង់ឡើងនៅខ្សែទឹកខាងលើ ដែលបង្កើនការទាញយកទឹកលើដីមកប្រើប្រាស់ និងនាំសំណល់ហូរចូលទៅសហគមន៍នៅខ្សែទឹកខាងក្រោម។ អ្នកលេងនៃខ្សែទឹកខាងលើ ត្រូវយកទឹកចំនួន ១ ពីអ្នកលេងនៃខ្សែទឹកខាងក្រោមម្នាក់ៗ ប្រសិនបើអ្នកលេងនៃខ្សែទឹកខាងក្រោម មានទីតាំងប្រើប្រាស់ទឹករួមរបស់សហគមន៍។

+1

USAID FROM THE AMERICAN PEOPLE · SWP SUSTAINABLE WATER PARTNERSHIP · WINROCK INTERNATIONAL

កាតឱកាសទីជម្រាល

សហគមន៍ខ្សែទឹកខាងលើបានវិនិយោគលើដីកសិរុក្ខកម្មបន្ថែម និងដីព្រៃនៅក្បែរប្រភពទឹកចេញពីក្រោមដី ដែលនាំឱ្យមានការកាត់បន្ថយការហូរច្រោះ និងបង្កើនគុណភាពទឹក ជាថ្នូរនឹងការទូទាត់សំណងពីសំណាក់សហគមន៍នៅខ្សែទឹកខាងក្រោម។ អ្នកលេងនៃខ្សែទឹកខាងក្រោមម្នាក់ៗ ត្រូវទូទាត់សងដល់សហគមន៍នៅខ្សែទឹកខាងលើម្នាក់ៗចំនួនសាច់ប្រាក់ ២ ហើយអ្នកលេងនៃខ្សែទឹកខាងលើ ត្រូវផ្តល់ឱ្យអ្នកលេងនៃខ្សែទឹកខាងក្រោមម្នាក់ៗ ចំនួនទឹក +១ ។

+2 +1

USAID FROM THE AMERICAN PEOPLE · SWP SUSTAINABLE WATER PARTNERSHIP · WINROCK INTERNATIONAL

កាតឱកាសទីជម្រាល

ដោយសារការសឹករេចរឹលព្រៃឈើ និងការបំពុលបរិស្ថាននៅខ្សែទឹកខាងលើ ជាហេតុធ្វើឱ្យវិស័យអេកូទេសចរណ៍នៅខ្សែទឹកខាងលើមានការថយចុះ ហើយផ្លាស់ប្តូរឆ្ពោះទៅរកសហគមន៍នៅខ្សែទឹកខាងក្រោមវិញ។ អ្នកលេងនៃខ្សែទឹកខាងលើ ត្រូវផ្តល់ឱ្យអ្នកលេងនៃខ្សែទឹកខាងក្រោមម្នាក់ៗ ចំនួនសាច់ប្រាក់២។

+2

USAID FROM THE AMERICAN PEOPLE · SWP SUSTAINABLE WATER PARTNERSHIP · WINROCK INTERNATIONAL

កាតឱកាសទីជម្រាល

ទំនប់មួយត្រូវបានសាងសង់ឡើងនៅខ្សែទឹកខាងលើនៃទីជម្រាល ដែលបណ្តាលឱ្យមានការប្រើប្រាស់ហួសកម្រិត និងថយចុះនូវធនធានទឹកនៅខ្សែទឹកខាងក្រោម។ ប្រសិនបើពួកគេមានកម្រិតពិន្ទុទឹកសហគមន៍ អ្នកលេងនៃខ្សែទឹកខាងក្រោមម្នាក់ៗ ត្រូវផ្តល់ឱ្យអ្នកលេងនៃខ្សែទឹកខាងលើម្នាក់ៗ ចំនួនទឹក២

+2

USAID FROM THE AMERICAN PEOPLE · SWP SUSTAINABLE WATER PARTNERSHIP · WINROCK INTERNATIONAL

កាតឱកាសទីជម្រាល

ការទាញទឹកយកមកប្រើប្រាស់ហួសកម្រិតពីខ្សែទឹកខាងលើ ជាហេតុនាំឱ្យមានទំនាស់ផលប្រយោជន៍ រវាងសហគមន៍នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម ធ្វើឱ្យមានបាតុកម្មបិទផ្លូវ ដែលជាគន្លឹះនៃខ្សែចង្វាក់តម្លៃ។ អ្នកលេងនៃខ្សែទឹកខាងលើ ត្រូវផ្តល់ឱ្យអ្នកលេងនៃខ្សែទឹកខាងក្រោមម្នាក់ៗ ចំនួនសាច់ប្រាក់១។

+1

Water Tokens

please cut along dotted lines





Money Tokens

please cut along dotted lines

៛ ៛ ៛ ៛ ៛ ៛

៛ ៛ ៛ ៛ ៛ ៛ ៛ ៛ ៛

៛ ៛ ៛ ៛ ៛ ៛ ៛ ៛ ៛

៛ ៛ ៛ ៛ ៛ ៛ ៛ ៛ ៛

៛ ៛ ៛ ៛ ៛ ៛ ៛ ៛ ៛

៛ ៛ ៛ ៛ ៛ ៛ ៛ ៛ ៛

៛ ៛ ៛ ៛ ៛ ៛ ៛ ៛ ៛